# **ងងឹតនិង ភ្លឺ**

| | |
|---|---|
| លោកអ្នកទាំងឡាយអើយ | ស្តាប់ធម៌ហើយពិចារណា |
| តើខ្លួនអ្នកយ៉ាងណា | យកបញ្ហាធ្ងុះឲ្យយល់ ។ |
| ងងឹត ឬមួយភ្លឺ | អកុសល ឬកុសល |
| ទុច្ចរិតនាំសល់រ៉ល់ | ព្រះទសពលថា ងងឹត ។ |
| សុចរិតចិត្តជ្រះថ្លា | តាមធម៌អាថ៌ដ៏ពិសិដ្ឋ |
| នេះឯងព្រះពិជិត | ត្រាស់ទុក្ខពិតហៅថាភ្លឺ ។ |
| ដើរតាមផ្លូវងងឹត | ឬ តាមផ្លូវមានពន្លឺ |
| អាក្រក់ល្អល្បីរន្ទឺ | ស្រេចនៅលើខ្លួនទាំងអស់ ។ |
| មិនមែនឥតហេតុផល | ឬឥន្ទព្រហ្មណាសាងសោះ |
| គឺខ្លួនឯងទាំងអស់ | ជាអ្នកសាងឲ្យខ្លួនឯង ។ |
| អ្នកដែលមកងងឹត | កុំតូចចិត្ត គួរគិតឈ្វេង |
| ខំប្រឹងដើរខ្លួនឯង | ងាកទៅរកផ្លូវភ្លឺវិញ ។ |
| ដួលហើយមិនព្រមក្រោក | ដេកក្នុងភក់ដូចម្តេចមិញ |
| ត្រូវតែក្រោកឡើងវិញ | លាងខ្លួនប្រាណដើរទៅទៀត។ |
| អ្នកដែលកំពុងភ្លឺ | កុំសប្បាយចោលម្យៀត |
| ប្រយ័ត្នធ្លាក់ខ្លួនទៀត | ទៅក្នុងផ្លូវងងឹតវិញ ។ |
| ភ្លឺហើយត្រូវភ្លឺទៀត | ឆ្លៀតហើយឆ្លៀតទើបចំណេញ |
| កុំឲ្យថយក្រោយវិញ | មិនងាយរើខ្លួនឡើយណា ។ |
| ជម្រាបន័យខ្លីៗ | យើងគប្បីពិចារណា |
| ហើយដឹកនាំអាត្មា | ទៅរកសុខ សួស្តីអើយ ៕ |

**ចាក មនុស្ស ឆ្នាំ និង មង្គលសូត្រ ឆ្នាំ ១៩៩៣**